**គួនាទី៖ជំនួយការផ្នែកទំនាក់ទំនង**
ខែ មីនា ឆ្នាំ២០២១

យើងគឺជា ៖

ល្ខោនគំនិត គឺជាក្រុមសិល្បៈករល្ខោនខ្មែរ ដែលបានចូលរួមនៅក្នុងសិល្បៈល្ខោននិយាយ, សិក្ខាសាលា, ក្នុងគម្រោងផ្សេងៗ និង ធ្វើការសម្តែង នៅក្នុងសហគមន៍ អង្គការផ្សេងៗ, សាលារៀន និង សកលវិទ្យាល័យ នៅក្នុងប្រទេសកម្ពុជា។

អង្គការល្ខោនគំនិត គឺជាអង្គការក្រៅរដ្ឋាភិបាល

ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅថ្ងៃទី07 ខែតុលា ឆ្នាំ2019។

ចក្ខុវិស័យ

អង្គការល្ខោនគំនិតមានចក្ខុវិស័យ ធ្វើឱ្យល្ខោននិយាយមានភាពល្បីល្បាញ និងត្រូវបានផ្តល់តម្លៃជាសិល្បៈប្រកបដោយអត្ថន័យខ្លឹមសារដែលជួយលើកកម្ពស់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។

បេសកម្ម

អង្គការល្ខោនគំនិតមានគោលដៅផ្តល់ឱកាសដល់ប្រជាជនកម្ពុជាក្នុងការចូលរួម ផលិត សម្តែង និងមើលល្ខោននិយាយជាពិសេសផ្តល់នូវបទពិសោធន៍ដែលជំរុញបញ្ញា និងស្មារតីអាចជាកាតាលីករសម្រាប់ការឆ្លុះបញ្ចាំង និងការអភិវឌ្ឍខ្លួន។

អង្គការល្ខោនគំនិត
LAKHON KOMNIT
organization

**តួនាទី៖** **ជំនួយការផ្នែកទំនាក់ទំនង (Communications Assistant)**

| | |
|---|---|
| រាយការណ៍ជូន៖ | ប្រធានផ្នែកទំនាក់ទំនង និងរៃអង្គាសមូលនិធិ |
| បុគ្គលទំនាក់ទំនងសំខាន់៖ | នាយកប្រតិបត្តិ ជំនួយការគម្រោង សិល្បៈករ |
| ប្រភេទការងារ៖ | ក្រៅម៉ោង ការងារមានរយៈពេលកំណត់ |
| ប្រាក់បៀវត្ស៖ | បៀវត្សដំបូងចំនួន 250 $ / ខែ (ពេញម៉ោងស្មើនឹង 315.5 ដុល្លារ)<br>ការដំឡើងប្រាក់បៀវត្សគឺអាស្រ័យលើលទ្ធផលការងារនៅក្នុងរយៈពេលសាកល្បង 3 ខែ។ |
| ម៉ោងការងារ និងទីតាំង៖ | ក្រៅម៉ោង 32 ម៉ោង / សប្តាហ៍៖ កាលវិភាគបត់បែន ចាប់ពីពីថ្ងៃចន្ទដល់ ថ្ងៃអាទិត្យ ទៅតាមការផ្លាស់ប្តូរកាលវិភាគសិក្ខាសាលា គម្រោង និងសកម្មភាពរបស់ LKO។<br>@ សិក្ខាសាលា LKO នៅទីរួមខេត្តបាត់ដំបង<br>កន្លែងផ្សេងទៀតនៅទីតាំងសិក្ខាសាលា និងគម្រោងតាមការចាំបាច់៖<br>ភាគច្រើននៅក្នុងខេត្តបាត់ដំបង<br>ដោយមានការធ្វើដំណើរម្តងម្កាលនៅក្នុងប្រទេសកម្ពុជា។ |

**បញ្ជាក់៖**
**LKO គឺជាអង្គការថ្មី ដែលមានក្រុមការងារតូចមួយ។ ដូច្នេះ វិសាលភាពការងារនៅក្នុងតួនាទីនីមួយៗនឹងមានលក្ខណៈទូលំទូលាយ និងផ្តោតទៅលើការអភិវឌ្ឍសមត្ថភាពបុគ្គល និងសម្ថភាពរបស់បុគ្គលិក និងការអភិវឌ្ឍការងាររបស់អង្គការ ដើម្បីសម្រេចគោលដៅរបស់យើង។ សមាជិកម្នាក់ៗត្រូវបំពេញការងារឱ្យអស់ពីសមត្ថភាព និងមានភាពបត់បែន ព្រមទាំងបើកចិត្តធ្វើការងារក្នុងតួនាទីផ្សេងៗគ្នាជូនអង្គការដែលកំពុងមានការរីកចម្រើន។**

អង្គការល្ខោនគំនិត
LAKHON KOMNIT
organization

<u>**សេចក្តីសង្ខេបអំពីតួនាទី (គោលបំណង)**</u>

គោលដៅចម្បង៖ បង្កើតឯកសារទំនាក់ទំនងផ្សេងៗដើម្បីចងក្រងឯកសារ និងជំរុញឱ្យមានការចូលរួមពីបុគ្គលជាច្រើនទៀតនៅក្នុងការងាររបស់ LKO។

**ទំនួលខុសត្រូវ៖**

- បង្កើនចំនួនអ្នកចូលទស្សនាទំព័រ Facebook និង YouTube របស់ LKO ដោយបង្កើត និងចែករំលែកខ្លឹមសារគួរឱ្យចាប់អារម្មណ៍ឱ្យបានទៀងទាត់
- បង្កើតលក្ខណៈពិសេសរបស់ LKO សម្រាប់វីដេអូនៅលើទំព័រ Facebook និង YouTube
- ផលិតវីដេអូចំនួនយ៉ាងតិច 1 ក្នុងមួយសប្តាហ៍ ដោយអនុវត្តតាមការណែនាំរបស់ LKO អំពីម៉ាកសញ្ញា និងរចនាបទ។
- ថតកម្មវិធីផ្សេងៗរបស់ LKO តាមរយៈការចូលរួមសិក្ខាសាលា ការសម្តែង និងគម្រោងនានា ដើម្បីថតរូប និងវីដេអូ។
- ថែរក្សាកន្លែងផ្ទុករូបថត និងវីដេអូឱ្យបានល្អ។

ចូលរួមចំណែក៖

- រៀបចំសេចក្តីព្រាង និងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងរបស់ LKO ឆ្នាំ2021
- រៃអង្គាសប្រាក់តាមរយៈការផ្តល់ និងផលិតរូបថត និងវីដេអូ ដើម្បីគាំទ្រការអនុវត្ត និងយុទ្ធនាការ
- ធ្វើរបាយការណ៍៖ តាមរយៈការផ្តល់ និងផលិតរូបថត វីដេអូ និងស្ថិតិផ្សេងៗ។
- សម្ភាសអ្នកពាក់ព័ន្ធ៖ អ្នកចូលរួម អ្នកទស្សនា អាជ្ញាធរជាដើម ដើម្បីបានដឹងអំពីប្រសិទ្ធភាព

លក្ខខណ្ឌ៖

- សម្រាប់តែជនជាតិខ្មែរ
- ឧទាហរណ៍បង្ហាញអំពីការងាររបស់អ្នក (រូបថត វីដេអូ។ល។)

*សម្គាល់៖ អ្នកពុំចាំបាច់មានគុណវុឌ្ឍិជាផ្លូវការទេ*
*យើងកំពុងស្វែងរកបុគ្គលដែលមានទេពកោសល្យនិងមានចំណង់ចំណូលចិត្តចូលរួមជាមួយក្រុមការងារដែលមានគំនិតថ្មៃប្រឌិត។*

ជំនាញសំខាន់ៗ៖

- និទានរឿងតាមរយៈប្រព័ន្ធបច្ចេកវិទ្យា
- ភ្នែកមុតសម្រាប់រូបភាព និងការរចនាផ្សេងៗ
- ជាអ្នកថតរូបដែលមានទំនុកចិត្តខ្ពស់
- មានបទពិសោធន៍លើការងាររៀបចំផែនការ ថតរូប និងកែសម្រួលវីដេអូ រួមទាំងការងារបញ្ចូលអក្សររត់ពីក្រោមវីដេអូ
- ចូលចិត្តទាក់ទងជាមួយមនុស្សទូទៅតាមរយៈបណ្ដាញសង្គមជា ជាពិសេស Facebook និង YouTube
- អាចជជែកអំពីគោលបំណង និងសកម្មភាពរបស់ LKO តាមរបៀបដែលមានភាពទាក់ទាញចំពោះបុគ្គលផ្សេងៗ

លក្ខណៈសំខាន់ៗ៖

- មានជំនាញទំនាក់ទំនងច្បាស់លាស់
- មានសមត្ថភាពក្នុងការកំណត់អាទិភាព និងគ្រប់គ្រងការងារផ្ទាល់ខ្លួន
- មានភាពស្មោះត្រង់ និងផ្ដល់ទំនុកចិត្តខ្ពស់
- មានឆន្ទៈក្នុងការសួរសំណួរ និងស្នើសុំជំនួយ
- យកចិត្តទុកដាក់រៀនសូត្រ អភិវឌ្ឍ និងបង្កើនជំនាញ
- មានភាពសមសួន ចេះគួរសម និងងាយស្រួលទំនាក់ទំនង

លក្ខណៈសម្បត្តិត្រូវមាន៖

- បទពិសោធន៍នៅក្នុងតួនាទីស្រដៀងគ្នា
- មានចំណាប់អារម្មណ៍ខ្លាំងលើសិល្បៈខ្មែរ

អង្គការល្ខោនគំនិត
LAKHON KOMNIT
organization

ភាសា៖ ភាសាខ្មែរ៖ ជាជនខ្មែរដែលមានជំនាញច្បាស់លាស់លើការនិយាយ និងសរសេរភាសាខ្មែរ

មានជំនាញភាសាអង់គ្លេសរឹតតែប្រសើរ ប៉ុន្តែបេក្ខជនដែលមានជំនាញច្បាស់លាស់ផ្នែករូបភាព និងវីដេអូ ប៉ុន្តែមានកម្រិត ឬគ្មានជំនាញភាសាអង់គ្លេសត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យស្នើសុំការងារនេះ។

សម្គាល់៖ នេះគឺជាតួនាទីថ្មី ហើយសេចក្តីពិពណ៌នាអំពីការងារអាចមានការផ្លាស់ប្តូរ និងប្រែប្រួលនៅពេលអង្គការរីកចម្រើន។ ការផ្លាស់ប្តូរនេះនឹងត្រូវពិភាក្សា និងមានការព្រមព្រៀងជាមួយបុគ្គលិកដែលកាន់មុខតំណែង។

## សម្រាប់សំណួរផ្សេងៗ

សូមទាក់ទង៖ lakhonkomnit@gmail.com // Facebook @lakhonkomnit // 070403495

## របៀបដាក់ពាក្យ

សូមផ្ញើប្រវត្តិរូបសង្ខេបរបស់អ្នក លិខិតអមម (cover letter) និងឧទាហរណ៍មួយចំនួនអំពីការងាររបស់អ្នក (រូបថត វីដេអូ បណ្តាញសង្គម) ទៅកាន់ lakhonkomnit@gmail.com។ កាលបរិច្ឆេទឈប់ទទួលពាក្យ៖ ថ្ងៃទី23 ខែមីនា ឆ្នាំ2021